ភ្នំពេញ ប៉ុស្តិ៍ The Phnom Penh Post

# អបអរខួប ២៩ ឆ្នាំ

# កាសែតភ្នំពេញ ប៉ុស្តិ៍

ថ្ងៃទី១០ ខែកក្កដា ១៩៩២ - ថ្ងៃទី១០ ខែកក្កដា ២០២១



**សារពីអគ្គនាយក**

# ភ្នំពេញ ប៉ុស្តិ៍ ក្នុងដំណើររយៈពេល២៩ឆ្នាំ នៅតែបន្តភាពរឹងមាំ និងសកម្ម

ខ្ញុំពិតជាមានមោទនភាពខ្លាំងណាស់ដែលបានចែករំលែកទស្សនៈរបស់ខ្ញុំ នៅក្នុងថ្ងៃប្រារព្ធខួបដ៏សំខាន់ ខណៈកាសែតភ្នំពេញប៉ុស្តិ៍បានឈានចូលខួប ២៩ឆ្នាំ នៅក្នុងថ្ងៃនេះ។

កាសែតភ្នំពេញប៉ុស្តិ៍បន្តប្រកាន់ខ្ជាប់នូវគោលការណ៍ស្នូលនៃសារព័ត៌មាន ដើម្បីនាំមកនូវព័ត៌មានប្រកបដោយគុណភាពដល់មិត្តអ្នកអានរបស់យើង និងចូលរួមចំណែកក្នុងវិជ្ជាជីវៈ ដល់ការកសាងប្រទេសជាតិ ជាអ្វីដែលយើងបានខិតខំប្រឹងប្រែងអស់រយៈពេលជិត៣ទសវត្សរ៍កន្លងមកនេះ ចាប់តាំងពីកាសែតត្រូវបានបោះពុម្ពផ្សាយជាលើកដំបូង។

ការទទួលបានជោគជ័យនេះគឺដោយសារយើងជឿជាក់លើសុចរិតភាពនៃអត្ថបទសារព័ត៌មានរបស់យើង ដែលមានតម្លាភាពមិនលម្អៀង និងគួរឱ្យទុកចិត្ត យើងនៅតែជាកញ្ចក់សម្រាប់សង្គម នោះហើយដែលធ្វើឱ្យយើងលេចធ្លោជាងគូប្រជែងរបស់យើង។

រយៈពេល២៩ឆ្នាំកន្លងមកនេះ យើងតែងតែរៀនសូត្រ និងរិះរកវិធីសាស្ត្រថ្មីៗ ដើម្បីធ្វើឱ្យប្រសើរឡើងនូវអត្ថបទ និងការចែកចាយព័ត៌មានរបស់យើង ខណៈប្រព័ន្ធផ្សព្វផ្សាយបានបន្តផ្លាស់ប្តូរហើយអ្នកអានមានជម្រើសកាន់តែច្រើនដើម្បីទទួលបានព័ត៌មាន។



លោក លី តៃសេង ចាងហ្វាង និងអគ្គនាយក កាសែតភ្នំពេញ ប៉ុស្តិ៍។

## ព្រឹត្តិការណ៍ឥតគ្រោងទុកបានកើតឡើង

គ្មានការសង្ស័យទេថា ឆ្នាំ២០២០ គឺជាឆ្នាំសាកល្បងដ៏តានតឹង។ ជីវិតរស់នៅ ទម្លាប់ និងរបៀបធ្វើអាជីវកម្មរបស់យើងបានផ្លាស់ប្តូរយ៉ាងខ្លាំង បន្ទាប់ពីការផ្ទុះឡើងនៃជំងឺកូវីដ១៩ នៅដើមឆ្នាំនោះ ហើយក៏បានបង្ហាញអំពីភាពខ្លាំង ភាពខ្សោយ និងភាពងាយរងគ្រោះរបស់យើង ចំពោះហានិភ័យដែលបានកើតឡើងដោយឥតព្រាងទុកនេះ។

បរិយាកាសថ្មីដែលយើងកំពុងរស់នៅ បង្ខំឱ្យយើងមិនត្រឹមតែកំណត់រចនាសម្ព័ន្ធអាជីវកម្មរបស់យើងឡើងវិញប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវពិនិត្យដោយយកចិត្តទុកដាក់ពីរបៀបដែលយើងផ្តល់ព័ត៌មានទៅដល់មិត្តអ្នកអានរបស់យើង។ វាជាបញ្ហាប្រឈមថ្មីសម្រាប់រូបខ្ញុំ និងសហការីរបស់ខ្ញុំ។ ការរៀបចំរចនាសម្ព័ន្ធរបស់ស្ថាប័នឡើងវិញ ត្រូវបានធ្វើឡើងនៅទាំងផ្នែកសរសេរព័ត៌មាននិងផ្នែកផ្សេងទៀត ពីព្រោះពួកគេត្រូវការពេលវេលាដើម្បីបំពេញការងារនៅក្នុង«បទដ្ឋានថ្មី»។

កាលវិភាគបំពេញការងាររបស់បុគ្គលិកត្រូវប្តូរវេន ដោយតម្រូវឱ្យធ្វើការពីផ្ទះ ដើម្បីរក្សាគម្លាតសង្គម ដែលត្រូវបានអនុវត្តយ៉ាងឆាប់រហ័ស ខណៈថ្នាក់ដឹកនាំយកចិត្តទុកដាក់ខ្ពស់ ចំពោះការការពារសុខភាពបុគ្គលិក។ ដូច្នេះហើយទើបធ្វើឱ្យយើង អាចបន្តការចេញផ្សាយអត្ថបទព័ត៌មានប្រចាំថ្ងៃបាន សម្រាប់មិត្តអ្នកអាន ទាំងក្នុង និងក្រៅប្រទេស ដោយគ្មានការអាក់ខាន។

## សម្លឹងហួសឆ្នាំ២០២១

យើងកំពុងកែលម្អ និងច្នៃប្រឌិត ដើម្បីនាំមកនូវព័ត៌មានដែលមានការប្រកួតប្រជែង ជាព័ត៌មានពិត និងគួរឱ្យជឿទុកចិត្ត ទាន់ហេតុការណ៍ និងមិនលម្អៀង ដល់អ្នកអានរបស់យើង ទាំងសម្រាប់កាសែតបោះពុម្ព និងតាមប្រព័ន្ធឌីជីថល។ ដើម្បីរក្សាការផ្តល់ព័ត៌មាននៅក្នុងប្រព័ន្ធបច្ចេកវិទ្យាដែលកំពុងមានការផ្លាស់ប្តូរ ជាពិសេសអំឡុងពេលមានជំងឺរាតត្បាត កាសែតភ្នំពេញប៉ុស្តិ៍បានបង្កើនសមត្ថភាពប្រកួតប្រជែងឌីជីថលរបស់ខ្លួន តាមរយៈការប្រើប្រាស់វេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា តេឡេក្រាម និងហ្វេសប៊ុក ដើម្បីទាក់ទាញអ្នកអានកាន់តែច្រើន។

យើងតែងតែពង្រឹងជំនាញរបស់យើងជានិច្ច ដើម្បីបន្តស្វែងយល់ពីតម្រូវការរបស់សង្គម ដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកផ្សព្វផ្សាយពាណិជ្ជកម្ម ហើយសំខាន់ជាងនេះទៅទៀតនោះ គឺមិត្តអ្នកអានដ៏ស្មោះស្ម័គ្ររបស់យើង ដែលតែងតែចង់បានព័ត៌មានដែលមានគុណភាព និងបំពេញមុខងារជាកាសែតឈានមុខគួរឱ្យទុកចិត្តនៅក្នុងបរិស្ថានថាមវន្ត។

## កាសែតរបស់ប្រជាជន

នៅថ្ងៃនេះ យើងបានឈានដល់ចំណុចដ៏សំខាន់មួយទៀត នៅក្នុងវិស័យសារព័ត៌មាននៅកម្ពុជា ខណៈកាសែតភ្នំពេញប៉ុស្តិ៍ជាភាសាអង់គ្លេស និងខេមរភាសា រួមបញ្ចូលគ្នាមានអ្នកអានប្រមាណ ៩លាននាក់នៅលើហ្វេសប៊ុក ធ្វើឱ្យយើងឈានមុខគេមួយនៅក្នុងកាសែតបោះពុម្ព និងឌីជីថល។ យើងកំពុងវិវឌ្ឍដោយប្រកាន់ខ្ជាប់នូវតម្លៃស្នូលរបស់យើង ហើយយើងនៅតែជា«កាសែតរបស់ប្រជាជន»។ ក្រុមការងារផ្នែកសារព័ត៌មានរបស់យើងបន្តលើកឡើងអំពីបញ្ហាសង្គម រាប់ចាប់តាំងពីការប្រែប្រួលអាកាសធាតុ បញ្ហាការងារ និងការលំបាករបស់ប្រជាពលរដ្ឋក្នុងអំឡុងពេលការផ្ទុះឡើងនៃជំងឺកូវីដ១៩ រហូតដល់ភាពក្រីក្រ និងបញ្ហាសិទ្ធិមនុស្ស នៅក្នុងចំណោមបញ្ហាដទៃជាច្រើនទៀត។

យើងបានក្លាយជាផ្នែកមួយនៃការផ្លាស់ប្តូរជាប្រវត្តិសាស្ត្រដែលព្រះរាជាណាចក្រកម្ពុជាបានឆ្លងកាត់ ហើយយើងនឹងបន្តធ្វើជាឧបករណ៍មួយសម្រាប់ការផ្លាស់ប្តូរ ដើម្បីសង្គមជាតិយើងបានល្អប្រសើរ។ យើងមានជំនឿចិត្តនៅក្នុងការបន្តដំណើរដ៏អស្ចារ្យនេះ ពីព្រោះយើងជឿជាក់ថា យើងកំពុងជម្នះបញ្ហាប្រឈម ហើយតួលេខក៏បានបញ្ជាក់ដូច្នេះ!

វាមិនត្រឹមតែជាចំនួន និងពានរង្វាន់ជាច្រើនដែលយើងបានទទួល ដែលធ្វើឱ្យយើងមានមោទនភាពប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាផ្នែកមួយនៃដំណើរដែលយើងបានមើលឃើញ អំពីភាពរីករាយ និងជោគជ័យក៏ដូចជាទុក្ខលំបាក ខណៈប្រទេសជាតិបានរីកចម្រើនឆ្ពោះទៅមុខ។

សមិទ្ធផលទាំងនេះនឹងមិនអាចសម្រេចទៅបាននោះទេ ប្រសិនបើគ្មានទំនុកចិត្ត និងការគាំទ្រដ៏ឥតងាករេ ពីបុគ្គលិក ក្រុមហ៊ុនផ្សព្វផ្សាយដៃគូអាជីវកម្ម និងមិត្តអ្នកអានរបស់យើង ក្នុងរយៈពេលនៃភាពជោគជ័យជាច្រើនឆ្នាំកន្លងមកនេះ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះទាំងអស់គ្នាដែលបានគាំទ្រ។

នៅក្នុងន័យនេះ ខ្ញុំសូមកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងព័ត៌មាន ដែលបានបង្កើតបរិយាកាសដ៏អំណោយផលដល់កាសែតភ្នំពេញប៉ុស្តិ៍ និងប្រព័ន្ធផ្សព្វផ្សាយទាំងបែបបុរាណ និងទំនើបដទៃទៀត ដើម្បីប្រតិបត្តិការដោយសេរី នៅក្រោមរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា។

ខណៈដែលយើងអបអរសាទរព្រឹត្តិការណ៍ដ៏សំខាន់នេះ យើងក៏នឹកចាំដល់មិត្តភក្តិរបស់យើង ជាពិសេសក្រុមគ្រួសាររបស់ពួកគេ ដែលបានរងគ្រោះ និងបាត់បង់ជីវិតដោយសារជំងឺកូវីដ១៩ ហើយយើងក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បុគ្គលិកសុខាភិបាល និងមន្ត្រីពាក់ព័ន្ធ ដែលបានខិតខំប្រឹងប្រែងធ្វើការដោយមិនខ្លាចនឿយហត់ អស់រយៈពេលជាច្រើនខែកន្លងមកនេះ ដើម្បីថែទាំអ្នកដែលត្រូវការជំនួយក្នុងអំឡុងពេលមានវិបត្តិសុខភាព ដែលមិនធ្លាប់មានពីមុនមកនេះ។ ខ្ញុំសូមគោរពជូនពរគ្រប់គ្នាឱ្យមានសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច៕

**អបអរសាទរខួបគម្រប់ ២៩ឆ្នាំ!**


















# ភ្នំពេញប៉ុស្តិ៍ជាកន្លែងផ្លាស់ប្ដូររបត់ថ្មីក្នុងជីវិតវិជ្ជាជីវៈ៖ ពីអ្នកស្វែងរកប្រភពព័ត៌មានមកជាអ្នកផ្ដល់ប្រភពព័ត៌មានសម្រាប់អ្នកសារព័ត៌មាន

នេត្រ ភក្ត្រា

**ភ្នំពេញ:** គិតត្រឹមថ្ងៃនេះ គឺមានរយៈពេលជាង ១០ឆ្នាំ ដែលខ្ញុំបានបញ្ចប់អាជីពជាអ្នកសារព័ត៌មានដែលខ្ញុំធ្លាប់បម្រើទាំងផ្នែកកាសែតបោះពុម្ព វិទ្យុ និងទូរទស្សន៍ក្នុងពេលតែមួយរយៈពេលជាង១០ឆ្នាំ មកជាមន្ត្រីនាំពាក្យ និងក្រោយមកជាប្រធានផ្នែកកិច្ចការសាធារណៈនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាត់សេចក្ដីលើឧក្រិដ្ឋកម្មដែលកើតឡើងក្នុងរបបខ្មែរក្រហម ហើយបច្ចុប្បន្ននេះបាននិងកំពុងបំពេញតួនាទីជារដ្ឋលេខាធិការ និងជាមន្ត្រីនាំពាក្យនៃក្រសួងបរិស្ថានសម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៦នៃនីតិកាលរដ្ឋសភា។ កន្លែងបំពេញអាជីពសារព័ត៌មានចុងក្រោយរបស់ខ្ញុំគឺនៅសារព័ត៌មានភ្នំពេញប៉ុស្តិ៍។

ខ្ញុំបានចូលបម្រើការងារនៅកាសែតនេះពីខែវិច្ឆិកា ឆ្នាំ២០០៨ ក្រោយកាសែត ២ ភាសាខ្មែរ-អង់គ្លេស ឌឺមេគង្គថៃមស៍ ដែលខ្ញុំជានិពន្ធនាយកបានបិទទ្វារដោយសារ ក្ស័យធន រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ក្នុងឋានៈជាអនុប្រធានក្រុមអ្នកព័ត៌មាន និងបន្ទាប់មកជានាយកគ្រប់គ្រងការីនិពន្ធកាសែតភ្នំពេញប៉ុស្តិ៍ភាសាខ្មែរ មុននឹងចាប់អាជីពថ្មីជាមន្ត្រីនាំពាក្យនៅតុលាការខ្មែរក្រហមនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១១។

ទោះបីពេលនេះ ខ្ញុំបានបញ្ចប់អាជីពសារព័ត៌មាន និងមិនមែនជាបុគ្គលិកកាសែតភ្នំពេញប៉ុស្តិ៍ទៀតក៏ដោយ តែបេះដូងកាយចិត្ត អារម្មណ៍ខ្ញុំនៅនឹងកាសែតនេះជានិច្ចហាក់ដូចជាសាច់ញាតិម្នាក់ ព្រោះខ្ញុំ និងសហការីមួយចំនួនទៀតបានប្រសូតកាសែតភ្នំពេញប៉ុស្តិ៍ជាភាសាខ្មែរនេះដោយផ្ទាល់ដៃចាប់តាំងពីការរៀបចំទស្សនទាន រៀបចំឡូហ្គោ ការរៀបចំរចនាទំព័រ បង្កើតក្រុមការងារ បណ្ដុះបណ្ដាលធនធានមនុស្សរហូតដល់ការរៀបចំយុទ្ធសាស្ត្រទីផ្សារ។

ជាកូនដែលបានបង្កើតផ្ទាល់ដៃ កាសែតភ្នំពេញប៉ុស្តិ៍ភាសាខ្មែរ ចាប់ផ្ដើមផ្សាយសាកល្បងនៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៩ និងចេញផ្សាយជាផ្លូវការប្រកួតប្រជែងជាមួយកាសែតផ្សេងទៀតនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៩។ កាសែតភ្នំពេញប៉ុស្តិ៍ភាសាខ្មែរ បានដើរទន្ទឹមគ្នាជាមួយកាសែតភ្នំពេញប៉ុស្តិ៍ភាសាអង់គ្លេស និងជាប្រភពព័ត៌មានដ៏គួរទុកចិត្តផ្លូវការរបស់សាធារណជន។ ក្នុងនាមស្ថាបនិកម្នាក់ ខ្ញុំពិតជាមាន មោទនភាព ក្រៃលែង ចំពោះកាសែតមួយនេះដែលបន្តឈរជើងរឹងមាំនៅលើទីផ្សារព័ត៌មាន រហូតមកទល់ពេលនេះប្រកបដោយភាពជឿជាក់និងជាប្រភពព័ត៌មានជាទីទុកចិត្តរបស់មិត្តអ្នកអានរបស់ខ្លួន។



**លោក នេត្រ ភក្ត្រា ពេលធ្វើការនៅកាសែតភ្នំពេញប៉ុស្តិ៍។ លោកលើកបង្ហាញកាសែតភ្នំពេញប៉ុស្តិ៍ជាភាសាខ្មែរដំបូង។** រូប ភ្នំពេញប៉ុស្តិ៍

កាសែតភ្នំពេញប៉ុស្តិ៍ ជាទីដែលបានធ្វើឱ្យខ្ញុំកាន់តែមានភាពរឹងមាំក្នុងអាជីពសារព័ត៌មាន ផ្ដល់បទពិសោធការងារ និងមានឱកាសយកទ្រឹស្ដីសិក្សានៅសាលាផ្នែកសារព័ត៌មាន បទពិសោធពីកម្មសិក្សានៅប្រទេសបារាំងមកអនុវត្តទាំងជំនាញសរសេរ និងជំនាញគ្រប់គ្រងក្នុងវិស័យសារព័ត៌មាន។

ទីនេះបានផ្ដល់នូវភាពកក់ក្ដៅ និងសាមគ្គីភាព មិត្តភាពក្នុងនាមជាសហភាតាក្នុងសមរភូមិស្លាបប៉ាកា។ ខ្ញុំមានអនុស្សាវរីយ៍យ៉ាងច្រើននៅទីនេះជាមួយមិត្តរួមការងារដែលមិនអាចបំភ្លេចបាន ដែលពេលនេះស្ថាបនិកមួយចំនួនបាននិងកំពុងបន្តបម្រើការងារ នៅទីនេះយ៉ាងស្វិតស្វាញ ដូចជា លោក សំ រិទ្ធ លោក វង្ស សុខេង លោក សូ វិសាល លោក ព្រុំ ភ័ក្ត្រ និងលោកស្រី ប៉ាន់ ស៊ីម៉ាឡា ជាដើម។

យើងបានឆ្លងកាត់ពេលវេលាដ៏លំបាកជាមួយគ្នា ធ្វើការដាច់យប់ជាមួយគ្នា សប្បាយរីករាយជាមួយគ្នា និងមានមោទនភាពរួមគ្នាក្រោមទិសស្លោក «ភ្នំពេញប៉ុស្តិ៍បម្រើកម្ពុជា»។ ពេលខ្លះទោះយើងមានទស្សនៈផ្សេងគ្នា តែយើងមានស្មារតីជាបងប្អូនប្រកៀកស្មាគ្នា ជួយគ្នាទៅវិញទៅមក តម្កល់ផលប្រយោជន៍រួម បម្រើមិត្តអ្នកអាន ខិតខំបំពេញការងាររហូតបានកសាងកេរ្ដិ៍ឈ្មោះសម្រាប់កាសែតភ្នំពេញប៉ុស្តិ៍នេះឡើង។ នេះគឺជាការសាងប្រវត្តិសាស្ត្រមួយក្នុងវិស័យសារព័ត៌មាននៅកម្ពុជា និយាយជារួម និង និយាយដោយឡែកសម្រាប់ ប្រវត្តិសាស្ត្ររបស់កាសែតភ្នំពេញប៉ុស្តិ៍ផ្ទាល់តែម្ដងដែលជាសារព័ត៌មាន បម្រើឱ្យការពិតរបស់កម្ពុជា។

រយៈពេលដែលខ្ញុំបំពេញការងារ នៅកាសែតភ្នំពេញប៉ុស្តិ៍ អ្វីដែលខ្ញុំមិនបានបំភ្លេចបានគឺកាសែតនេះ បានដើរតួនាទីយ៉ាងសំខាន់ជាសំឡេងកម្ពុជាអំឡុងពេលជម្លោះរវាង កម្ពុជានិងថៃនៅតំបន់ប្រាសាទព្រះវិហារនិងជាមធ្យោបាយផ្ដល់ព័ត៌មានពិតអំពីកម្ពុជាទៅកាន់សាធារណជន។ ព្រឹត្តិការណ៍ដ៏សោកសៅនៃការរត់ជាន់គ្នានៅលើស្ពានកោះពេជ្រនាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០ ក៏ជាផ្នែកមួយនៃការចងចាំរបស់ខ្ញុំក្នុងបទពិសោធក្នុងអាជីពសារព័ត៌មានថាតើបន្ទាត់និពន្ធត្រូវបត់បែននិងរត់តាមសភាពការណ៍ថ្មីៗយ៉ាងណា និងបញ្ជាក់ថា តើការងារជាអ្នកសារព័ត៌មានត្រូវមានការទទួលខុសត្រូវយ៉ាងណាពេលមានហេតុការណ៍សំខាន់កើតឡើង ហើយតើមន្ត្រីនាំពាក្យត្រូវធ្វើសកម្មភាពបែបណាករណីមានវិបត្តិកើតឡើងដូច្នេះដើម្បីគ្រប់គ្រងសាធារណមតិ។ អ្វីដែលសប្បាយចិត្តពេលថ្នាក់ដឹកនាំ ពិសេសសម្ដេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍លើកពីឈ្មោះ កាសែតភ្នំពេញប៉ុស្តិ៍ក្នុងសុន្ទរកថា និងពេលខ្លះលើកបង្ហាញរូបភាពកាសែតជាសាធារណៈដូចជាព័ត៌មានទាក់ទងនឹងលោកតា រួមរឹតមិត្តភក្តិរបស់ព្រះបរមរតនកោដ្ឋជាដើម។ សារព័ត៌មានបានដើរតួនាទីយ៉ាងសំខាន់ចូលរួមគ្រប់គ្រងសភាពការណ៍ប្រទេសជាតិ ចូលរួមធ្វើឱ្យមានស្ថិរភាពជាតិ និងការយល់ដឹងរបស់ប្រជាពលរដ្ឋដោយផ្ដល់ព័ត៌មានពិតរហ័សនិងទុកចិត្តដោយឈរលើមូលដ្ឋានប្រភពព័ត៌មានច្បាស់លាស់។ ដោយឆ្លងកាត់ការប្រឡូកក្នុងអាជីពជាអ្នកសារព័ត៌មានជាង១០ឆ្នាំ និងក្នុងអាជីពជាមន្ត្រីនាំពាក្យជាង ១០ឆ្នាំមកនេះ ខ្ញុំពិតជាអរគុណនូវអាជីពសារព័ត៌មានរួមនឹងបទពិសោធ ចំណេះដឹង ចំណេះធ្វើ ដែលខ្ញុំធ្លាប់បំពេញការងារចាប់ផ្ដើមចេញពីកម្មវិធីព័ត៌មានភាសាបារាំង Rendezvous របស់ស្ថានីយទូរទស្សន៍ជាតិកម្ពុជា កាសែតសំណេរថ្មី កាសែតឌឺមេគង្គថៃមស៍ វិទ្យុបារាំងអន្តរជាតិ ផលិតកម្មខ្មែរមេគង្គ និងចុងក្រោយគឺកាសែតភ្នំពេញប៉ុស្តិ៍ ដែលបានធ្វើឱ្យខ្ញុំមានបទពិសោធការងារគ្រប់គ្រាន់ និងមានមូលដ្ឋានវិជ្ជាជីវៈរឹងមាំក្នុងការបោះជំហានលើអាជីពថ្មីពីអ្នកស្វែងរកប្រភពព័ត៌មានមកជាអ្នកផ្ដល់ប្រភពព័ត៌មានសម្រាប់អ្នកសារព័ត៌មាន នោះគឺតួនាទីជា «មន្ត្រីនាំពាក្យ» ដែលខ្ញុំបាននិងកំពុងបំពេញសម្រាប់សាលាក្ដីខ្មែរក្រហមក្នុងនាមជាប្រធានផ្នែកកិច្ចការសាធារណៈ និងក្នុងនាមជារដ្ឋលេខាធិការ និងជាមន្ត្រីនាំពាក្យក្រសួងបរិស្ថាន៕



អរគុណសន្តិភាព អរគុណភ្នំពេញប៉ុស្តិ៍ អរគុណអតីតសហភាតា!

**(លោក នេត្រ ភក្ត្រា ជារដ្ឋលេខាធិការ និងជាមន្ត្រីនាំពាក្យក្រសួងបរិស្ថាន)** ■


ស័ក្តិសម
បំផុតសម្រាប់អ្នក
ចូលចិត្តម្ហូបអាហារ
ថ្មី!
BATTAMBANG'S FINEST RICE
SINCE 1933
ANCHOR
WHITE
EXTRA REFRESHING
PREMIUM QUALITY
18+
ពិសាដោយការទទួលខុសត្រូវ


ROYAL GROUP
អបអរសាទរថ្ងៃគម្រប់ខួប
២៩ ឆ្នាំក្នុង
ប្រទេសកម្ពុជា
The Phnom Penh Post
សារជូនពរពី ក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប
ROYAL GROUP


កាន់តែងាយស្រួល ផ្ទេរប្រាក់រហូតដល់
$150.000 ក្នុងមួយថ្ងៃឥតគិតថ្លៃ
ពីគណនីវីង ទៅគណនីវីង
ធនាគារ វីង (ខេមបូឌា) ម.ក
(+855)23 999 989 | (+855)12 999 489
WingMoney
Wing


អបអរសាទរ ខួបលើកទី២៩ នៃកាសែតភ្នំពេញប៉ុស្តិ៍
CONGRATULATIONS PHNOM PENH POST ON YOUR 29TH ANNIVERSARY
HYATT REGENCY
HYATT REGENCY PHNOM PENH
GBAC STAR FACILITY
#HYATTREGENCYPHNOMPENH
MARKET CAFÉ RESTAURANT & LOUNGE
DAILY
7:00 AM - 10:00 PM
THE ATTIC
WEDNESDAY - SATURDAY
5:00 PM - 12:00 AM
FIVEFIVE ROOFTOP RESTAURANT & BAR
WEDNESDAY - SUNDAY
4:00 PM - 10:00 PM
Telegram: 855 97 300 1234 | Email: phnompenh.regency@hyatt.com | hyattregencyphnompenh.com


PhillipBank
PhillipCapital Singapore
គេហដ្ឋានថ្មី និងការធានារ៉ាប់រង
រហូតដល់
$70,000
ឥណទានរហូតដល់ 85%
កម្ចីរហូតដល់ 25ឆ្នាំ
អត្រាការប្រាក់/ឆ្នាំ 7.99%
ចាប់ពីថ្ងៃទី21 ខែមិថុនា ដល់ថ្ងៃទី20 ខែតុលា ឆ្នាំ2021
*លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្ត
086 930 000 / 089 989 818
PhillipBank Cambodia
info@phillipbank.com.kh
www.phillipbank.com.kh

# លោកស្រី Tracey Shelton ៖ សមិទ្ធផលដ៏អស្ចារ្យនិងអនុស្សាវរីយ៍ដែលគួរឱ្យគោរពគឺបានមកពីឆ្នាំដែលខ្ញុំបានចំណាយពេលនៅកាសែតភ្នំពេញប៉ុស្តិ៍

Tracey Shelton

ខ្ញុំជាអ្នកថតរូបអាជីពវ័យក្មេងម្នាក់ពេលដែលឈានជើងចូលការិយាល័យកាសែតភ្នំពេញប៉ុស្តិ៍ក្នុងឆ្នាំ២០០៥។

ការងាររបស់ខ្ញុំបានប្រមូលផ្ដុំរូបថតពីកសិដ្ឋានប៉ារបស់ខ្ញុំនៅក្នុងប្រទេសអូស្ត្រាលី សេចក្ដីពិពណ៌នាអំពីរូបភាពពីស្ទូឌីយោនោះខ្ញុំបានធ្វើការដោយតក់ក្រហល់ ដោយជ្រើសរើសរូបភាពដែលមានពីទូទាំងពិភពលោកក្នុងអំឡុងពេល ៤ ឬ៥ឆ្នាំចុងក្រោយដែលជាអ្នកថតរូបដូចជាក្រុមល្បាតនាវា។

យ៉ាងណាក៏ដោយ រូបភាពទាំងនោះវាគ្រប់គ្រាន់គួរសមក្នុងការដាក់ពិន្ទុ ដល់ការងារជាយថាហេតុនៅក្នុងក្រុមអ្នកសារព័ត៌មាន នៅក្នុងបន្ទប់ព័ត៌មាន ដែលត្រូវបានចាត់តាំងជាលើកដំបូង ក្នុងការងារជាអ្នកថតរូបអាជីពដែលគ្មានស្ថាប័នឬក្រុមហ៊ុន ខ្ញុំដើរតត្រុកចុះតត្រុកឡើងថតរូបក្មេងរាំតាមផ្លូវ និងអណ្ដើកចម្លែកនៅក្នុងវត្ត។

ក្ដីសុបិនរបស់ខ្ញុំគឺធ្វើអ្វីឱ្យមានភាពខុសប្លែកពីគេក្នុងពិភពលោក ហើយខ្ញុំបានមើលឃើញថា វិជ្ជាជីវៈសារព័ត៌មានជាឱកាសសម្រាប់ខ្ញុំក្នុងការប្រើជំនាញរបស់ខ្ញុំដើម្បីលាតត្រដាងនូវអ្វីដែលខុស ប្រយុទ្ធប្រឆាំងនឹងការរើសអើង ការយល់ច្រឡំ និងការធ្វើពិធីឱ្យប្លែកពីគ្នា។

ព្រះរាជាណាចក្រកម្ពុជាគឺជាផ្ទះទី២របស់ខ្ញុំ។ ខ្ញុំបានធ្វើជាអ្នកស្ម័គ្រចិត្តនៅទីនោះ( កម្ពុជា )នៅពេលដែលខ្ញុំនៅក្មេង និងត្រង់។ នៅពេលនេះខ្ញុំសង្ឃឹមថា ខ្ញុំនឹងត្រឡប់មកកម្ពុជាវិញជាមួយអ្វីបន្ថែមដល់ខ្ញុំជាច្រើនទៀត។

នៅពេលនោះ ការិយាល័យព័ត៌មាននៃគេហដ្ឋានដែលមានបន្ទប់ខ្វាត់ខ្វែង រាត់រាយ នោះគឺជាផ្ទះលោក ម៉ៃឃើល ហេដែលជាស្ថាបនិក និងជាអ្នកគ្រប់គ្រងការីនិពន្ធបរទេស។ ខ្ញុំទទួលស្គាល់ថា នៅពេលដំបូងភាពគំរោះគំរើយខាងក្រៅរបស់លោកបានធ្វើឱ្យខ្ញុំភ័យតក់ស្លុត។ ប៉ុន្តែឆ្លងកាត់ពេលវេលាជាច្រើនឆ្នាំនៅកាសែតភ្នំពេញប៉ុស្តិ៍ ខ្ញុំបានចាប់ផ្ដើមកោតសរសើរគាត់យ៉ាងខ្លាំង ទាំងក្នុងនាមជាមិត្តម្នាក់ និង ជាមនុស្សម្នាក់នៅកម្ពុជា ត្រូវបានចាត់ទុកជាអ្នកបង្កើតមូលដ្ឋាននៃប្រព័ន្ធផ្សព្វផ្សាយដ៏រឹងមាំ។

ក្នុងរយៈពេលតែប៉ុន្មានសប្ដាហ៍ ខ្ញុំមិនត្រឹមតែជាអ្នកថតរូបប៉ុណ្ណោះទេប៉ុន្តែខ្ញុំបានចាប់ផ្ដើមសរសេរព័ត៌មានដោយផ្ទាល់ ដោយមានការបង្ហាត់បង្រៀន និងការជំរុញលើកទឹកចិត្តពីប្រធានការីនិពន្ធ លោក ឆាល ម៉ាដើរីដ ( Charles McDermid )លោកស្រី ស៊ូសានផុសវ៉ៃ ( Susan Postlewaite ) និង លោក សេត មិសន័រ ( Seth Meixner )។ នៅទីបំផុតខ្ញុំបានធ្វើឱ្យខ្លួនឯងក្លាយទៅជាអ្នកនិពន្ធរូបថត និងដឹកនាំក្រុមអ្នកថតរូបបានល្អបំផុតនៅក្នុងទីក្រុងភ្នំពេញ( ទោះបីយ៉ាងណាខ្ញុំអាចមានភាពលម្អៀងបន្តិចបន្តួចលើប្រធានបទនៃរូបថតនោះ! )។

ក្រៅពីជាអ្នកថតរូបដ៏អស្ចារ្យម្នាក់ ខ្ញុំមានឯកសិទ្ធិធ្វើការជាមួយអ្នកយកព័ត៌មានបរទេសដ៏អស្ចារ្យមួយចំនួន។ ខ្ញុំនៅមានមិត្តជាច្រើនរហូតដល់សព្វថ្ងៃនេះប៉ុន្តែការបំផុសគំនិតដ៏ធំបំផុតមកឱ្យខ្ញុំគឺជាមិត្តរួមការងារជនជាតិខ្មែរដែលបានបង្រៀនខ្ញុំពីអ្វីដែលជាវិជ្ជាជីវៈសារព័ត៌មានពិតប្រាកដ។



លោកស្រី Tracey Shelton ពេលទៅយកព័ត៌មាននៅព្រះវិហារ។ រូបថត សហការី

បច្ចេកទេសនៃការធ្វើសម្ភាសន៍របស់ខ្ញុំបានរីកចម្រើនតាមការឃ្លាំមើល លោក សំ រិទ្ធ ដែលលោកតែងតែមានឥរិយាបថក្នុងការផ្ដល់ឱ្យមនុស្សគ្រប់គ្នាមានភាពងាយស្រួល។ អ្នកនៅរស់រានមានជីវិតត្រូវបានលើករឿងផ្ទាល់ខ្លួនមកនិយាយខណៈដែលអ្នកផ្សេងទៀតមិនយល់ថា ពួកគេស្ថិតនៅក្នុងសភាពគ្រោះថ្នាក់នៅក្នុងតំបន់ក្ដៅដែលត្រូវបានដាក់សំណួរខ្លាំងទៅកាន់សន្តិសុខដើម្បីឈ្លេចយកចម្លើយ។

លោក វង្ស សុខេង អ្នកមានជំនាញក្នុងបណ្ដាការងារលើសលប់ប៉ុន្តែខ្ញុំចូលចិត្តធ្វើការជាមួយលោក ជាង សុខា (កាលគាត់នៅមានជីវិត )ជាពិសេសក្នុងពេលចុះទៅកាន់តំបន់ដែលមានកើតហេតុ នៅក្នុងប្រទេស យើងយកព័ត៌មាននិងសរសេររួមគ្នាហើយតំបន់ដែលខ្ញុំមានការចងចាំបំផុតនោះគឺរឿងប្រឈមមុខដាក់គ្នាដោយកងទ័ពកម្ពុជានិងថៃនៅតំបន់ប្រាសាទព្រះវិហារព្រំដែនកម្ពុជា-ថៃ។ ការប្រឈមមុខដាក់គ្នាយូរ បានផ្ទុះជាសង្គ្រាម នៅពេលដែលទទួលបានព័ត៌មានភ្លាម សុខាបានដោះស្រាយបញ្ហា ដោយសុំធ្វើដំណើរតាមឡានរបស់លោកហេង ស៊ីនិត្យ អ្នកថតរូបឱ្យភ្នាក់ងារAPប្រចាំក្រុងភ្នំពេញពួកយើងបានចាកចេញពីការិយាល័យដោយបន្ទាន់បំផុត។

ក្នុងសម្លៀកបំពាក់បែបធ្វើការក្នុងការិយាល័យ និងស្បែកជើងកែង មានថ្មកាមេរ៉ាតែ១ដុំគ្មានផ្ទាំងសាកថ្ម អ្នកទាំងនោះទទូចឱ្យប្រញាប់ ដោយមិនមានពេលឈប់នៅផ្ទះរបស់ខ្ញុំដើម្បីរៀបចំសម្ភារសម្រាប់យកទៅធ្វើការ។ ខ្ញុំមិនចាប់អារម្មណ៍ទេនៅពេលដែលយើងឈប់នៅមុខផ្ទះរបស់លោកសុខា ប៉ុន្តែភាពជាក់ស្ដែងគឺទៅយកគាត់ជួយ។យើងបានចំណាយពេលបើកឡានពេញ១យប់ ហើយរកកន្លែងគេងដោយចងអង្រឹងក្រោមដើមឈើនៅជើងភ្នំ មុនពេលចេញដំណើរបន្តទៀតទៅកាន់កំពូលភ្នំដែលមានភាពស្រអាប់ដែលគ្របដណ្ដប់លើប្រាសាទព្រះវិហារនៅពេលថ្ងៃរះ។

ទោះបីជាមានសម្លៀកបំពាក់មិនសមរម្យគ្រប់គ្រាន់នៅក្នុងខ្សែត្រៀមជួរមុខនៅកណ្ដាលព្រៃ ខ្ញុំបានត្រៀមខ្លួនក្នុងការប្រើកាមេរ៉ាដែលមានថ្មតែមួយដុំ ពេលនោះខ្ញុំក្លាយជាអ្នកយកព័ត៌មាននិងថតរូប។

នៅពេលមានភ្លៀងធ្លាក់ ភក់បានស្អិតជាប់ជិតស្បែកជើងកែងរបស់ខ្ញុំបាក់ខូច ខ្ញុំមិនបានត្អូញត្អែរសូម្បីម្ដង នៅទីនោះ នៅពេលដែលបុរសទាំងនោះមុជទឹករួចនិងស្លៀកពាក់ស្អាតបាតមករកខ្ញុំដើម្បីនាំទៅផឹកស្រាបៀរ។ ការអត់ធ្មត់ខ្ពស់របស់ខ្ញុំនៅក្នុងពេលដែលពួកគេនិយាយលែងកំប្លែងខ្លី ខ្ញុំត្រូវតែដឹងថា តើពួកគេមុជទឹកនៅកន្លែងណា នៅពេលដែលខ្ញុំមិនដឹងថាទៅមុជទឹកនៅទីណា ខកខានដុសធ្មេញ៤ថ្ងៃមកហើយនោះ។លក្ខណៈដែលមិនឆេវឆាវរបស់ខ្ញុំ ខ្ញុំបានរកកន្លែងមុជទឹកឃើញ និងទទួលបានអំណោយជាដបសាប៊ូកូនក្មេង កន្សែងនិងអាវពីលោកស៊ីនិត្យ ពិតណាស់អាវនោះពណ៌ស( លោកស៊ីនិត្យ ចូលចិត្តស្លៀកពាក់ពណ៌ស )។

ក្នុងចំណោមអនុស្សាវរីយ៍ដ៏អស្ចារ្យមានមេរៀនដ៏មានតម្លៃជាច្រើន និងជាដំបូងជាច្រើនរបស់ខ្ញុំ រូបថតទំព័រមុខរបស់ខ្ញុំព័ត៌មានស៊ើបអង្កេតលើកដំបូងរបស់ខ្ញុំការទទួលបានការជួយជាលើកដំបូងរបស់ខ្ញុំក្នុងអំឡុងពេលកុបកម្ម បាតុករវ័យក្មេងម្នាក់បានទាញខ្ញុំចេញពីផ្លូវដែលមានភ្នក់ភ្លើងកំពុងឆេះ មុនពេលគេនិយាយហ៊ឹមៗថាសុំទោសលោកស្រី ដោយលើកកណ្ដាប់ដៃ និងរត់ត្រឡប់ចូលទៅក្នុងហ្វូងមនុស្សវិញ។

បទពិសោធទាំងនេះបានបង្កើតមូលដ្ឋានគ្រឹះនៃអាជីពរបស់ខ្ញុំ ហើយបន្ទាប់ពីរយៈពេលជិត៥ឆ្នាំដ៏អស្ចារ្យនៅកាសែតភ្នំពេញប៉ុស្តិ៍ ខ្ញុំបានបន្តក្លាយជាអ្នកឆ្លើយឆ្លងព័ត៌មានបរទេសដែលនិយាយអំពីសង្គ្រាម និងការរំលោភសិទ្ធិមនុស្សនៅមជ្ឈិមបូព៌ា។

ខ្ញុំបានត្រឡប់មកប្រទេសកម្ពុជាវិញដើម្បីមកលេងផ្ទះទី២ និងគ្រួសារទី២ របស់ខ្ញុំជារៀងរាល់ឆ្នាំចាប់តាំងពីពេលនោះមក ហើយខ្ញុំមិនដែលខកខានឱកាសជួបជុំគ្នាជាមួយក្រុមការងារបុរសៗនិងចងចាំអនុស្សាវរីយ៍ដ៏អស្ចារ្យទាំងនោះទេ។

ប៉ុន្តែនៅឆ្នាំនេះ ចំពេលមានការហាមឃាត់ការធ្វើដំណើរដោយសារវិបត្តិកូវីដ១៩ ដែលរារាំងខ្ញុំមិនឱ្យនៅទីនោះដោយផ្ទាល់ យើងបានខកចិត្តដោយការបាត់បង់មិត្តជាទីស្រឡាញ់របស់យើងឈ្មោះ សុខា ដែលត្រូវបានទទួលមរណភាពធ្វើឱ្យឃ្លាតពីក្រុមគ្រួសារទាំងវ័យក្មេងដោយសារជំងឺមួយរំពេច។

ខណៈពេលយើងទាំងអស់គ្នានឹកគាត់ជាទីបំផុត គាត់តែងតែរស់នៅក្នុងដួងចិត្តរបស់យើងនៅក្នុងរឿងរ៉ាវរបស់យើង និងតាមរយៈអ្នកយកព័ត៌មានជាច្រើនដែលគាត់បានបង្រៀន និងបំផុសគំនិតដូចជាខ្ញុំដែរ។

បទពិសោធដែលខ្ញុំទទួលបាននិងមនុស្សដែលខ្ញុំបានជួបក្នុងពេលខ្ញុំនៅកាសែតភ្នំពេញប៉ុស្តិ៍មិនត្រឹមតែខ្ញុំក្លាយជាអ្នកកាសែតប៉ុណ្ណោះទេ ប៉ុន្តែខ្ញុំក៏ជាមនុស្សម្នាក់ក្នុងចំណោមនោះផងដែរ។

ក្នុងនាមជាអ្នកសារព័ត៌មានវ័យក្មេងម្នាក់ដែលក្រឡេកមើលរូបថតដែលតុបតែងនៅនឹងជញ្ជាំងពីអ្នកឆ្លើយឆ្លងព័ត៌មានសង្គ្រាមដោយឆ្លុះបញ្ចាំងពីឱកាសម្ដងម្កាលក្នុងការជ្រើសរើសការគិតរបស់អ្នកថតរូបល្បីល្បាញនៅក្នុងសង្គ្រាមគឺលោកធិម ផេក ( Tim Page ) ឬលោក អាល់ រ៉កកហ្វ ( Al Rockoff )នៅពេលផឹកស្រាបៀរ ខ្ញុំមិនដែលនឹកស្រមៃថាខ្ញុំនឹងបន្តសរសេរប្រវត្តិខ្លួនឯងទេ។

ខ្ញុំនៅជួរមុខនៅពេលដែលលោក ហ្គាដាហ្វី ( Muamar-Gaddafi ) ត្រូវបានចាប់ខ្លួនហើយបានប្រាប់ពិភពលោកនៃការស្លាប់របស់គាត់នៅក្នុងប្រទេសលីប៊ី។ ខ្ញុំមានឯកសិទ្ធិក្នុងការចងក្រងឯកសារ អំពីភាពធន់និងការឈឺចាប់របស់ក្រុមគ្រួសារ និងអ្នកប្រយុទ្ធដែលបានជាប់នៅក្នុងសង្គ្រាមនៅប្រទេសស៊ីរី។ ខ្ញុំនៅទីនោះ នៅទីតាំងដ៏បរិសុទ្ធបំផុតនៃជំនឿយ៉ាហ្ស៊ីឌី នៅក្នុងប្រទេសអ៊ីរ៉ាក់នៅពេលដែលក្រុមរដ្ឋអ៊ិស្លាមដណ្ដើមកាន់កាប់ភូមិរបស់ពួកគេ ការចាប់ជំរិតសម្លាប់ និងបំផ្លាញសហគមន៍ទាំងមូល។

ទោះបីជាយ៉ាងណាក៏ដោយ សមិទ្ធផលដ៏អស្ចារ្យនិងអនុស្សាវរីយ៍ដែលគួរឱ្យគោរពរបស់ខ្ញុំគឺបានមកពីឆ្នាំដែលខ្ញុំបានចំណាយពេលនៅកាសែតភ្នំពេញប៉ុស្តិ៍៕

( ប្រែសម្រួល ដោយ វ៉ាស៊ី ) ■



លោកស្រី Tracey និងសហការីអ្នកថតរូបភ្នំពេញប៉ុស្តិ៍។ រូបថត សហការី

# លោក ប៊ូ សារឿន៖ អ្នកយកព័ត៌មានមិនមែនជាសត្រូវ ប៉ុន្តែគឺជាបណ្ដាញព័ត៌មានរបស់អ្នក

ប៊ូ សារឿន

ពេលវេលាពិតជាដើរលឿនណាស់។ អស់រយៈពេលជិត ២០ឆ្នាំហើយ ដែលខ្ញុំបានចាកចេញពីកាសែតភ្នំពេញប៉ុស្តិ៍ ប៉ុន្តែវាមានអារម្មណ៍ថាហាក់ដូចកាលពីម្សិលមិញ។ ក្នុងនាមជាអតីតអ្នកយកព័ត៌មានកាសែតភ្នំពេញប៉ុស្តិ៍ ខ្ញុំមានសេចក្ដីសោមនស្សរីករាយក្នុងការអបអរសាទរខួបលើកទី២៨ របស់កាសែតភ្នំពេញប៉ុស្តិ៍ ហើយខ្ញុំសង្ឃឹមថាភ្នំពេញប៉ុស្តិ៍នៅតែអាចដើរតួនាទីសំខាន់ក្នុងការផ្ដល់រឿងរ៉ាវប្រកបដោយតុល្យភាពដល់អ្នកអានទាំងក្នុង និងក្រៅប្រទេស។

ខ្ញុំចាប់ផ្ដើមធ្វើការនៅកាសែតភ្នំពេញប៉ុស្តិ៍ក្នុងឆ្នាំ១៩៩៦ ក្នុងនាមជាអ្នកគ្រប់គ្រងការិយាល័យ។ តួនាទីរបស់ខ្ញុំនៅពេលនោះគឺគ្រាន់តែធ្វើយ៉ាងណាឱ្យមានសៀវភៅកត់ត្រា ប៊ិក ម៉ាស៊ីន ឬកូនម៉ាញ៉េថតសំឡេង និងគ្រឿងបរិក្ខារផ្សេងៗទៀត ដើម្បីឱ្យការិយាល័យដំណើរការបានរលូន ហើយខ្ញុំក៏បានស្ម័គ្រចិត្តសង្ខេបប៉ូលិសប្លិធ័រ( the Police Blotter )ដែលជាផ្នែកមានប្រជាប្រិយបំផុតមួយរបស់ភ្នំពេញប៉ុស្តិ៍។

តួនាទីជាអ្នកគ្រប់គ្រងការិយាល័យមិនមែនជាការងារដែលខ្ញុំចូលចិត្តនោះទេ ខ្ញុំចង់ធ្វើជាអ្នកយកព័ត៌មាន។ តាំងពីខ្ញុំនៅក្មេងនៅភូមិដាច់ស្រយាលមួយក្នុងខេត្តស្វាយរៀងជាកន្លែងដែលគ្មានវិទ្យុនិងគ្មានទូរទស្សន៍ស្ដាប់ឬមើលផង តែខ្ញុំចង់ធ្វើជាអ្នកនិទានរឿង។ ខ្ញុំបានឃើញមនុស្សកាន់មីក្រូហ្វូននៅលើឆាកឬនៅឯការជួបជុំនិងពិធីបុណ្យនានាខ្ញុំចង់ធ្វើដូចពួកគាត់ដែរ។ នៅពេលខ្ញុំលេងជាមួយមិត្តភក្តិក្មេងៗខ្ញុំតែងតែកាន់មែកឈើធ្វើជាក្បាលមីក្រូរបស់ខ្ញុំប្រាប់រឿងរ៉ាវឬរាយការណ៍ពីនេះពីនោះដល់ពួកគេ។

ខ្ញុំបានស្វែងរកឱកាសដើម្បីបំពេញក្ដីសុបិនរបស់ខ្ញុំក្នុងការក្លាយជាអ្នកយកព័ត៌មាន។ក្នុងនាមជាអ្នកគ្រប់គ្រងការិយាល័យខ្ញុំបានមើលពីរបៀបដែលអ្នកយកព័ត៌មាននៅភ្នំពេញប៉ុស្តិ៍ជ្រើសរើសនិងសរសេររឿងរ៉ាវរបស់ពួកគាត់។ ខ្ញុំបាននិយាយជាមួយពួកគាត់ហើយសុំយោបល់អំពីរបៀបក្លាយជាអ្នកយកព័ត៌មាន។

នៅពាក់កណ្ដាលឆ្នាំ ១៩៩៧ ឱកាសរបស់ខ្ញុំបានមកដល់។ លោក ម៉ៃឃីល ហេ( Michael Hayes ) ដែលជាអតីតអ្នកបោះពុម្ពផ្សាយកាសែតភ្នំពេញប៉ុស្តិ៍បានអនុញ្ញាតឱ្យខ្ញុំរួមដំណើរជាមួយគាត់ទៅតំបន់មួយដែលមានការប្រយុទ្ធតទល់គ្នារវាងកងទ័ពខ្មែរក្រហម និងកងកម្លាំងរដ្ឋាភិបាលចម្រុះនៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។



**លោក ប៊ូ សារឿន សម្ភាសជាមួយប្រភពពេលលោកបម្រើការងារជាអ្នកយកព័ត៌មាននៅកាសែតភ្នំពេញប៉ុស្តិ៍។** រូបថត សហការី

វាជាបទពិសោធគួរឱ្យរំភើប និងអស្ចារ្យ ហើយនៅពេលត្រឡប់មកពីសមរភូមិវិញ គាត់យល់ព្រមឱ្យខ្ញុំធ្វើជាអ្នកយកព័ត៌មានដោយគាំទ្រដល់វគ្គបណ្ដុះបណ្ដាលមួយទល់នឹងមួយដល់ខ្ញុំលើជំនាញសារព័ត៌មាន។

ខ្ញុំបានក្លាយជាកូនសិស្សរបស់លោក មឿន ឈានណារិទ្ធ ដែលខ្ញុំតែងតែអរគុណដល់ការបណ្ដុះបណ្ដាលដ៏អស្ចារ្យរបស់គាត់ ហើយបន្ទាប់មកខ្ញុំបានក្លាយជាអ្នកយកព័ត៌មាន១រូប។

ដោយសារប្រវត្តិ និងកុមារភាពរបស់ខ្ញុំនៅក្នុងតំបន់សង្គ្រាមរវាងសហរដ្ឋអាមេរិក និងវៀតណាមក្នុងអំឡុងដើមទសវត្សរ៍ ឆ្នាំ១៩៧០ ហើយក្រោយមកទៀត គឺសង្គ្រាមរវាងប៉ុលពត និងវៀតណាមនៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ៧០។ បន្ទាប់មកដំណើរទៅសរសេររឿងលើកដំបូងរបស់ខ្ញុំជាមួយ លោកម៉ៃឃីល ហេ នៅតំបន់ប្រយុទ្ធ ដូច្នេះការចាប់ផ្ដើមលើកដំបូងរបស់ខ្ញុំគឺសរសេរអំពីសន្តិសុខនិងការប្រយុទ្ធគ្នា( កិច្ចការសង្គ្រាម ) ជាពិសេសលើរបបខ្មែរក្រហម និងរដ្ឋប្រហារខែកក្កដា ឆ្នាំ១៩៩៧។

នៅពេលសង្គ្រាមស៊ីវិលបានបញ្ចប់ ការផ្ដោតលើប្រធានបទរបស់ខ្ញុំបានផ្លាស់ប្ដូរបន្តិចម្ដងៗដោយប្ដូរទៅសរសេរអំពីបញ្ហាសិទ្ធិមនុស្ស បញ្ហាសង្គម និងនយោបាយ ហើយបញ្ចប់ដោយផ្ដោតលើប្រធានបទកសិកម្ម និងបរិស្ថាន។

ខ្ញុំបានឈប់ពីមុខនាទីជាអ្នកយកព័ត៌មាននៅពាក់កណ្ដាលឆ្នាំ២០០២ ហើយក្លាយជាមន្ត្រីទទួលបន្ទុកកិច្ចការសាធារណៈនៅទីភ្នាក់ងារមួយរបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិនៅកម្ពុជា( the UN agencies in Cambodia )។ ខ្ញុំនៅតែអរគុណដល់កាសែតភ្នំពេញប៉ុស្តិ៍ អរគុណលោកម៉ៃឃីល ហេ លោកស្រី ខាលឡេនអូខេហ្វី ( Kathleen O’Keefe )( ដែលបានទទួលមរណភាពក្នុងឆ្នាំ២០១៤ ) និងចំពោះអ្នកកែសម្រួលនិពន្ធរបស់កាសែតភ្នំពេញប៉ុស្តិ៍ និងអ្នកសារព័ត៌មានទាំងអស់ដែលបានផ្ដល់ឱកាស និងគាំទ្រខ្ញុំក្នុងដំណើរជាអ្នកកាសែតកន្លងមក។

ដូច្នេះតើអ្វីខ្លះដែលខ្ញុំបានយកជំនាញជាអ្នកយកព័ត៌មានទៅអនុវត្តក្នុងតួនាទីបច្ចុប្បន្នជាមន្ត្រីកិច្ចការសាធារណៈរបស់ខ្ញុំ ?នៅក្នុងខួបលើកទី២៨ នៃកាសែតភ្នំពេញប៉ុស្តិ៍ខ្ញុំសូមលើកយក ៣ចំណុចដែលខ្ញុំបានរៀនសូត្រ មកចែករំលែកជាមួយមិត្តរួមអាជីពក្នុងប្រព័ន្ធផ្សព្វផ្សាយ និងអ្នកផ្សេងទៀតដែលចាប់អារម្មណ៍។

ទី១គឺការបង្កើតភាពជឿជាក់ និងប្រភពដែលអាចទុកចិត្តបាន។ សម្រាប់អ្នកសារព័ត៌មានការកសាងទំនុកចិត្ត និងទំនាក់ទំនងដែលអាចទុកចិត្តបានគឺជាវិធីដើម្បីទទួលបានព័ត៌មានត្រឹមត្រូវ។ នៅពេលប្រភពទុកចិត្តយើង ពួកគាត់មានអារម្មណ៍និយាយ និងចែករំលែកព័ត៌មានដោយសុវត្ថិភាព។ការជឿទុកចិត្តនៅទីនេះមានន័យថាជាការគោរពប្រភព គោរពសិទ្ធិរបស់ពួកគាត់ សន្តិសុខ និងសុវត្ថិភាពរបស់ពួកគាត់ ការសម្ងាត់ ការហាមឃាត់និងអ្វីៗផ្សេងទៀត។ នៅក្នុងការងារបច្ចុប្បន្នខ្ញុំបានបង្កើតការជឿទុកចិត្តក្នុងចំណោមបណ្ដាញនានាដែលរួមមាន មន្ត្រីរដ្ឋាភិបាល វិស័យឯកជន អង្គការសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយយុវជន និងសហគមន៍ជនបទ។

ទី២ បំបែកគំនិតដែលថា អ្នកសារព័ត៌មានជាសត្រូវឬជាអ្នកបង្កបញ្ហា។ នៅពេលដែលមនុស្សឮអ្នកយកព័ត៌មានទូរស័ព្ទទៅ ឬចោទសួរសំណួរ ពួកគេគិតថា អូព្រះជាម្ចាស់ ខ្ញុំមានបញ្ហាឬយើងកំពុងមានបញ្ហា។ ពួកគេភ័យស្លន់ស្លោ ពីព្រោះពួកគេអាចគិតថា អ្នកកាសែតទូរស័ព្ទ ឬសួរនៅពេលមានបញ្ហាអវិជ្ជមាន ឬមានរឿងមិនល្អ។ តាមពិតអ្នកធ្វើការផ្នែកប្រព័ន្ធផ្សព្វផ្សាយ ឬអ្នកកាសែតអាចផ្ដល់ឱកាសដល់យើងដើម្បីបញ្ជាក់ ឬបកស្រាយបញ្ហាអ្វីមួយដែលគេចោទប្រកាន់ ហើយផ្ដល់ជាបណ្ដាញសម្រាប់ទទួលបានព័ត៌មានអំពីការងារ ឬសមិទ្ធផលរបស់អ្នក។ អ្នកសារព័ត៌មានអាជីពមិនមែនជាសត្រូវទេ។ ពួកគេគឺជាបណ្ដាញសម្រាប់ទទួលនិងបញ្ជូនព័ត៌មាន។

ទី៣ គឺកសាងទស្សនៈប្រកបដោយតុល្យភាព។ នេះជាចំណុចសំខាន់ដោយសារនៅពេលអ្នកសរសេររឿងរបស់អ្នកពីមុំ ឬជ្រុងមួយដែលមានតុល្យភាពវានឹងនាំអ្នកឱ្យគិតអំពីទស្សនៈប្រកបដោយតុល្យភាពនៅពេលបំពេញភារកិច្ចផ្សេងទៀត។ នៅពេលអ្នកកំពុងធ្វើការនៅក្នុងកិច្ចការសាធារណៈអ្នកក៏ត្រូវស្នើឱ្យផ្ដល់ដំបូន្មានដល់អ្នកឬក្រុមគ្រប់គ្រងរបស់ស្ថាប័នរបស់អ្នកផងដែរ។នៅពេលដែលអ្នកគ្រប់គ្រងរបស់អ្នកទទួលបានទស្សនៈមិនលម្អៀង និងទិដ្ឋភាពពេញលេញអំពីស្ថានភាពនានាពួកគាត់អាចធ្វើការសម្រេចចិត្តដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដែលគាំទ្រដល់ប្រទេស និងប្រជាជនរបស់យើង។

ឧទាហរណ៍នៅពេលអ្នកដឹកនាំការប្រជុំពិគ្រោះយោបល់នានា ទស្សនៈប្រកបដោយតុល្យភាពរបស់អ្នកនឹងជួយអ្នកឱ្យគិតយ៉ាងទូលំទូលាយអំពីអ្នកណាដែលគួរតែត្រូវបានអញ្ជើញឱ្យពិគ្រោះពិភាក្សា។ បន្ទាប់មក អ្នកនឹងគិតពីអ្នកតំណាងមកពីគ្រប់មជ្ឈដ្ឋានដូចជា សហគមន៍ជនបទ ក្រុមងាយរងគ្រោះស្ត្រី និងកុមារ អ្នកស្រឡាញ់ភេទដូចគ្នា( បុរសស្រឡាញ់ភេទដូចគ្នា ស្ត្រីស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំង២ភេទ អ្នកប្ដូរភេទ និង intersex ( LGBTI )និងអ្នកផ្សេងទៀតជាដើម )។

ជាថ្មីម្ដងទៀត ខ្ញុំសង្កត់ធ្ងន់លើក្ដីសង្ឃឹមរបស់ខ្ញុំថា កាសែតភ្នំពេញប៉ុស្តិ៍អាចបន្តដើរតួនាទីសំខាន់ក្នុងការផ្ដល់នូវរឿងរ៉ាវប្រកបដោយតុល្យភាពលើប្រទេសកម្ពុជា។ ខ្ញុំសូមជូនពរដល់បុគ្គលិកកាសែតភ្នំពេញប៉ុស្តិ៍ទាំងអស់សូមមានសុវត្ថិភាព!

**( លោកប៊ូ សារឿន ជាមន្ត្រីកិច្ចការសាធារណៈនៃការិយាល័យធនាគារពិភពលោកប្រចាំនៅកម្ពុជា។ នេះជាការផ្ដល់មតិយោបល់លេចចេញពីគំនិតផ្ទាល់របស់លោក។ )** ■

> ***តាមពិតអ្នកធ្វើការផ្នែកប្រព័ន្ធផ្សព្វផ្សាយឬអ្នកកាសែតអាចផ្ដល់ឱកាសដល់យើងដើម្បីបញ្ជាក់ឬបកស្រាយបញ្ហាអ្វីមួយ ដែលគេចោទប្រកាន់ ហើយផ្ដល់ជាបណ្ដាញសម្រាប់ទទួលបានព័ត៌មានអំពីការងារឬសមិទ្ធផលរបស់អ្នក។ អ្នកសារព័ត៌មានអាជីពមិនមែនជាសត្រូវទេ...***

# ទស្សនៈមិត្តអ្នកអានចំពោះកាសែតភ្នំពេញប៉ុស្តិ៍

ឡុង គីមម៉ារីតា

កាសែតភ្នំពេញប៉ុស្តិ៍ ត្រូវបានបង្កើតឡើង កាលពីខែកក្កដា ឆ្នាំ១៩៩២ ដែលគិតរហូតមកទល់ខែកក្កដាឆ្នាំ ២០២១ នេះ មានអាយុកាល២៩ឆ្នាំហើយ។

ចាប់តាំងពីចាប់ផ្ដើមដំណើរការ និងរហូតមកទល់បច្ចុប្បន្ននេះ កាសែតភ្នំពេញប៉ុស្តិ៍ទាំងភាសាខ្មែរ និងអង់គ្លេសគឺនៅតែឈរនៅលំដាប់កំពូលក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូរបែបនៅក្នុងប្រទេសកម្ពុជា ខាងការផ្ដល់ព័ត៌មានពិត សុក្រឹត ឯករាជ្យ មានគុណភាព និងជឿទុកចិត្ត។

ខាងក្រោមនេះ គឺជាទស្សនៈចម្រុះគ្នា របស់មិត្តអ្នកអានដែលរួមមាន អ្នកវិភាគ មន្ត្រីរដ្ឋាភិបាល និងអ្នកមានជំនាញក្នុងវិស័យសារព័ត៌មាន ចំពោះកាសែតភ្នំពេញប៉ុស្តិ៍ ក្នុងឱកាសអបអរសាទរគម្រប់ខួប ២៩ឆ្នាំ របស់កាសែតភ្នំពេញប៉ុស្តិ៍ ៖

លោក ប៉ែន បូណា ប្រធានក្លឹបអ្នកកាសែតកម្ពុជា ដែលជាអ្នកតាមដានព័ត៌មានកាសែតភ្នំពេញប៉ុស្តិ៍ តាំងពីកាសែតនេះបើកដំបូងនិយាយថា៖«ខ្ញុំពីមុនគឺខ្ញុំតែងតែទទួលបានជាកាសែតបោះពុម្ព តែឥឡូវមិនសូវបានអានកាសែតបោះពុម្ពនោះប៉ុន្មានទេ គឺយូរៗខ្ញុំទិញកាសែតម្ដងដែរ ប៉ុន្តែភាគច្រើនតាមហ្វេសប៊ុកផេករបស់ភ្នំពេញប៉ុស្តិ៍»។

ចំពោះភាពងាយស្រួលទទួលបានព័ត៌មានពីភ្នំពេញប៉ុស្តិ៍លោក ប៉ែន បូណា បាននិយាយថា៖ «ដូចជាមិនលំបាកអីទេ ដូចតែយើងអានរាល់ដងហ្នឹង គឺយើងអានព័ត៌មានរាល់ថ្ងៃតាមភ្នំពេញប៉ុស្តិ៍នោះដែរ។ ព័ត៌មានដែលខ្ញុំចូលចិត្តអានពីភ្នំពេញប៉ុស្តិ៍ គឺព័ត៌មានថ្មីៗដែលកើតឡើងក្ដៅៗ និងព័ត៌មានសេដ្ឋកិច្ច»។

លោក បញ្ជាក់ថា៖«និយាយតាមត្រង់ទៅ ឥឡូវនេះ កាសែតមានភាពស្រដៀងៗគ្នា ទៅនឹងព័ត៌មានតាមវេបសាយ ហើយបើគិតថា យើងជាកាសែតបោះពុម្ព តែយើងក៏មានពហុប្រព័ន្ធផ្សព្វផ្សាយដែរ។ ប៉ុន្តែបើយើងជាកាសែតបោះពុម្ពផ្សាយ ហើយជាកាសែតភាសាបរទេសទៀត ព័ត៌មានដែលខ្ញុំ មើលទៅប្រហាក់ប្រហែលគ្នាដែរទៅនឹងស្ថាប័នដទៃ ។ យ៉ាងណា មានព័ត៌មានខ្លះ ដូចជា ព័ត៌មានសេដ្ឋកិច្ចពីភ្នំពេញប៉ុស្តិ៍ គឺលឿន និងប្លែកពីគេ»។ លោកបន្តថា៖ «តាមយោបល់ខ្ញុំ ភ្នំពេញប៉ុស្តិ៍ ទី១ យើងជាកាសែតអង់គ្លេសខ្ញុំចង់ឱ្យភ្នំពេញប៉ុស្តិ៍ហ្នឹង ក្លាយជាកាសែតមួយ ដែលអាចធ្វើជាឯកសារយោង ដែលឱ្យកាសែតផ្សេងៗក្នុងតំបន់ ក្នុងពិភពលោក អាចដកស្រង់ធ្វើជាអំណះអំណាងសម្រាប់ព័ត៌មានរបស់គេ»។

លោកបន្ថែមថា៖«ខ្ញុំឃើញថាបើអាចភ្នំពេញប៉ុស្តិ៍ គួរតែពង្រឹងកម្រិតគុណភាពរបស់យើងឱ្យខ្ពស់ជាងហ្នឹង។ ឧទាហរណ៍យើងគួរមានអ្នកវិភាគ ដែលមានសមត្ថភាពខាងវិភាគបញ្ហាក្នុងស្រុក បញ្ហាក្នុងតំបន់ និងបញ្ហាធំៗនៅក្នុងពិភពលោក ព្រោះយើងជាកាសែតភាសាបរទេស ដែលមានអ្នកអានជាខ្មែរផង ជាបរទេសផង ដើម្បីផ្ដល់ចំណេះដឹងដល់ខ្មែរនិងបរទេសគេចាប់អារម្មណ៍តាមដាន»។

លោកផុស សុវណ្ណ អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មានវិទ្យា និងជាអ្នកនាំពាក្យក្រសួងព័ត៌មាន ដែលបានតាមដានព័ត៌មានពីភ្នំពេញប៉ុស្តិ៍តាំងពីមុនឆ្នាំ ២០០៧ បាននិយាយថា៖«ខ្ញុំភាគច្រើនទទួលព័ត៌មានពីភ្នំពេញប៉ុស្តិ៍តាមរយៈប្រព័ន្ធតេឡេក្រាមច្រើនជាង ព្រោះខ្ញុំប្រើប្រាស់វាជាប្រចាំ។ ខ្ញុំត្រូវការផ្ទៀងផ្ទាត់ព័ត៌មានច្រើន ដូច្នេះខ្ញុំតាមដានចំណងជើងនៅលើហ្នឹង ហើយបានមកអានកាសែតដែលតែងតែមាននៅលើតុធ្វើការរបស់ខ្ញុំជារៀងរាល់ព្រឹក»។

លោកបន្តថា៖«ចំពោះភាពងាយស្រួលវិញ សម្រាប់ខ្ញុំ គឺស្រួលហើយ ព្រោះខ្ញុំចូលចិត្តតាមដានព័ត៌មានចម្រុះ ដូច្នេះឱ្យតែព័ត៌មាន ខ្ញុំតែងតែអាន ហើយជ្រើសរើសព័ត៌មានចាំបាច់ដែលអាចយកមកប្រើការបាន។ ខ្ញុំ នៅតែត្រូវការការបោះពុម្ពកាសែត តាមរយៈសន្លឹកក្រដាសដដែល ដោយសារតែខ្ញុំ មានអត្ថបទកាសែតនេះ មកដល់លើតុខ្ញុំ ហើយខ្ញុំត្រូវមើលឡើងវិញកន្លែងខ្លះ ព្រោះតែអត្ថបទច្រើនពេកនៅលើប្រព័ន្ធអ៊ីនធឺណិត»។

ចំពោះប្រធានបទ ឬប្រភេទព័ត៌មានដែលភ្នំពេញប៉ុស្តិ៍មិនទាន់បានផ្សាយ ហើយចង់ឱ្យមានផ្សព្វផ្សាយ លោក ផុស សុវណ្ណ បាននិយាយថា៖«មិនមែនតែខ្ញុំទេ សូម្បីឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មានក៏ចង់ឃើញ ហើយតាមពិតភ្នំពេញប៉ុស្តិ៍បានធ្វើច្រើនហើយលើទំព័រអ្នកថ្មី។ ប៉ុន្តែយើងចង់ឱ្យមានទំព័រមួយដែលវាល្អ សម្រាប់អ្នកខ្លាំងអ្នកដែលពូកែផ្នែកណាមួយគួរតែមានរំលេចទុកលើទំព័រកាសែតទៅ។ បានន័យថា ទំព័រ១ហ្នឹង បង្ហាញគាត់ថាគាត់ខ្លាំងអីគេគ្រូបង្រៀនល្អ មេឃុំល្អ ចៅហ្វាយខេត្តល្អ កម្មករល្អ ឱ្យក្លាយទៅជាទំព័រគំរូមួយ ហើយចំណុចហ្នឹង គឺត្រូវមានលើទំព័រកាសែតហ្នឹងជាប្រចាំតែម្ដង ដែលយើងចូលចិត្តដឹងតែម្ដង»។



សន្តិសុខម្នាក់ កំពុងអានកាសែតភ្នំពេញប៉ុស្តិ៍នៅកន្លែងយាម។ រូប ជីវ៉ន



អ្នករត់កង់៣ម្នាក់អានកាសែតភ្នំពេញប៉ុស្តិ៍ពេលរង់ចាំភ្ញៀវ។ រូប ជីវ៉ន

លោក ប៉ា ចន្ទរឿន ជាប្រធានវិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា ដែលតែងតែអានភ្នំពេញប៉ុស្តិ៍ជាប្រចាំ ហើយក៏ជាអ្នកផ្ដល់បទសម្ភាសឱ្យភ្នំពេញប៉ុស្តិ៍ជាញឹកញាប់ផងនោះបានថ្លែងថា លោកតែងតែអានព័ត៌មានពីកាសែតភ្នំពេញប៉ុស្តិ៍តាមរយៈប្រព័ន្ធផ្សព្វផ្សាយចម្រុះ មិនថាជាលក្ខណៈកាសែត វេបសាយតេឡេក្រាមឬហ្វេសប៊ុកនោះទេ ព្រោះភ្នំពេញប៉ុស្តិ៍មានទាំងភាសាខ្មែរ និងអង់គ្លេស ដែលអាចទទួលបានព័ត៌មានទាំងក្នុង និងក្រៅប្រទេស។

លោកបញ្ជាក់ថា៖«ខ្ញុំបានអានកាសែតភ្នំពេញប៉ុស្តិ៍តាំងពីខ្ញុំរៀនថ្នាក់បរិញ្ញាបត្រ ប៉ុន្តែកាលនោះមិនបានទិញផ្ទាល់ទេ គឺទៅចូលអាននៅការិយាល័យរបស់សាលា។ កាលនោះ គឺយូរហើយ ព្រោះអ៊ីនធឺណិត យើងមិនទាន់សម្បូរបែបដូចសព្វថ្ងៃ គឺមានតែអានភ្នំពេញប៉ុស្តិ៍ជាកាសែត»។

លោកបាននិយាយបន្តថា៖ «ខ្ញុំ តែងតែអានព័ត៌មានសេដ្ឋកិច្ច សង្គម វប្បធម៌ នយោបាយ ការអប់រំ ដែលត្រូវនឹងជំនាញខ្ញុំហ្នឹង។ ខ្ញុំពេញចិត្តនឹងជំហររបស់ភ្នំពេញប៉ុស្តិ៍ ទោះបីជាមានការផ្លាស់ប្ដូរ ម្ចាស់ ឬក៏នយោបាយយើងក៏ដោយ ក៏ភ្នំពេញប៉ុស្តិ៍នៅតែមានជំហរអព្យាក្រឹតច្រើន បើប្រៀបធៀបនឹងកាសែតដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ខ្ញុំ សង្ឃឹមថា ភ្នំពេញប៉ុស្តិ៍ នឹងប្រកាន់ជំហរជាកាសែតឯករាជ្យ ហើយរក្សាគោលជំហររបស់ខ្លួន ជាស្ថាប័នព័ត៌មានពិតប្រាកដមួយក្នុងការផ្ដល់ព័ត៌មានពិត ដល់ពលរដ្ឋ និងភាគីពាក់ព័ន្ធ»។

បន្ថែមពីនេះលោក ប៉ា ច័ន្ទរឿនក៏ចង់ឃើញកាសែតភ្នំពេញប៉ុស្តិ៍ បញ្ចូលអត្ថបទព័ត៌មានខ្លះទាក់ទងនឹងវប្បធម៌ និងសីលធម៌សង្គម ឬក៏គំរូល្អមួយចំនួន ដែលមាននៅក្នុងសង្គមយើង ដើម្បីជាទុនសម្រាប់ប្រជាពលរដ្ឋយកជាគតិ ឬជាគំរូ ក្នុងការបង្ហាញពីទិដ្ឋភាពវិជ្ជមាននៃសង្គមខ្មែរ។

លោក ព្រុំ សុខា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រិយមិត្តរបស់កាសែតភ្នំពេញប៉ុស្តិ៍ ចាប់តាំងពីកាសែតនេះចាប់កំណើតឡើងដំបូង បានស្វាគមន៍ចំពោះការបន្តប្រតិបត្តិការរបស់កាសែតភ្នំពេញប៉ុស្តិ៍និងសង្ឃឹមថា កាសែតនេះនឹងបន្តការផ្សព្វផ្សាយព័ត៌មានក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍកម្ពុជា។

លោកបន្តថា៖«ព័ត៌មានដែលផ្សាយចេញដោយកាសែតភ្នំពេញប៉ុស្តិ៍ គឺជាព័ត៌មាន ដែលអាចឱ្យអ្នកអានយកមកប្រើប្រាស់បាននិងមានប្រភពច្បាស់ៗក្នុងព័ត៌មាននីមួយៗ។ ភ្នំពេញប៉ុស្តិ៍ដែលបានឈរជើងដល់សព្វថ្ងៃ គឺមានន័យថា បានចូលរួមដល់ដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា សម្រាប់បម្រើឱ្យអ្នកអានក្នុងការពង្រីកព័ត៌មានចម្រុះ»។

ជាមួយនឹងការបន្តគាំទ្រនេះ លោកព្រុំ សុខា បានបញ្ជាក់ថា៖ «ខ្ញុំនៅតែទទួលបានព័ត៌មានយ៉ាងសម្បូរបែបពីកាសែតភ្នំពេញប៉ុស្តិ៍ មិនថា ជាកាសែតបោះពុម្ព ឬតាមប្រព័ន្ធផ្សព្វផ្សាយនានា របស់ស្ថាប័នភ្នំពេញប៉ុស្តិ៍នោះទេ ខ្ញុំទទួលបានគ្រប់ទាំងអស់។ ខ្ញុំចាត់ទុកថាកាសែតបោះពុម្ព គឺនៅតែមានសារប្រយោជន៍ ហើយខ្ញុំគាំទ្រដល់ការផ្សព្វផ្សាយជាភាសាខ្មែរ សម្រាប់ពលរដ្ឋខ្មែរ ដែលកាលពីមុនយើងមានតែភាសាបរទេសទេ ដូច្នេះសម្រាប់អ្នកចេះភាសាអង់គ្លេសបានតិច គាត់អាចតាមដានអានតាមភាសាខ្មែរបានដែរ»៕ ■


ភ្ញៀវនៅហាងអាហារមួយកំពុងអានកាសែតភ្នំពេញប៉ុស្តិ៍។ រូបថត ហេង ជីវ៉ន

# ភ្នំពេញប៉ុស្តិ៍ បន្តលើកស្ទួយវប្បធម៌ សិល្បៈ ទេសចរណ៍ និងម្ហូបអាហារ

ភ្នំពេញ ប៉ុស្តិ៍



ទិដ្ឋភាពទឹកធ្លាក់អូរយ៉ះ ឬទឹកធ្លាក់កោះប៉ង់ ដើរតួនាទីសំខាន់មួយក្នុងការស្ទួយសេដ្ឋកិច្ចសហគមន៍ជនជាតិដើមភាគតិចចំនួន ២ នៃ ឃុំកោះប៉ង់ ខេត្តរតនគិរី។ រូបថត យូសុះ អាប់ឌុលរ៉ាស់ហ៊ីម

អំឡុងដើមទសវត្សរ៍ឆ្នាំ១៩៩០ មានភោជនីយដ្ឋានល្បីៗតិចតួច ដូចជា ហង្សនាគ និងហេង ឡាយ ស្ថិតនៅតាមផ្លូវជាតិលេខ ៦អា ម៉ុំព្រៃកលៀប ហើយចំពោះកន្លែងដើរលេងពេញនិយម វាហាក់ដូចជាគ្មានអ្វីលើសពីសួនមុខព្រះបរមរាជវាំង តំបន់មាត់សមុទ្រ និងប្រាង្គប្រាសាទអង្គរវត្ត ខណៈទេសចរណ៍ធម្មជាតិគឺសូន្យ។

ទេសចរណ៍សហគមន៍ ឬអេកូទេសចរណ៍ ស្ថិតក្នុងតំបន់គ្រោះថ្នាក់នៃចម្ការមីន និងដែនដីមួយផ្នែកត្រូវបានគ្រប់គ្រងដោយក្រុមខ្មែរក្រហម ដែលធ្វើឱ្យភ្ញៀវទេសចរមិននឹកនាដល់ដំណើរកម្សាន្តបែបធម្មជាតិឡើយ។

ពីមួយថ្ងៃទៅមួយថ្ងៃ ហើយពីមួយឆ្នាំទៅមួយឆ្នាំទៀត របៀបរបបនៃការរស់នៅកាន់តែមានការអភិវឌ្ឍ កម្ពុជាមើលឃើញពីកំណើននៃចំនួនភោជនីយដ្ឋាន អាហារដ្ឋាន តូបអាហារតាមចិញ្ចើមផ្លូវជាមួយមុខម្ហូបដ៏សម្បូរបែប ក៏ដូចជា រមណីយដ្ឋាន រីសត តំបន់អេកូទេសចរណ៍ រួមទាំង តន្ត្រីភាពយន្ត និងវិចិត្រសាលសិល្បៈបន្តរីកដុះដាលព្រោងព្រាត។

រយៈពេលជិត៣ទសវត្សរ៍មកនេះ កាសែតភ្នំពេញប៉ុស្តិ៍ បាននិងកំពុងតែចូលរួមចំណែកយ៉ាងសំខាន់ មិនត្រឹមតែផ្តល់នូវព័ត៌មានផ្នែកនយោបាយ សន្តិសុខសង្គម និងសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែណែនាំទីកន្លែងកម្សាន្តថ្មីដ៏គួរឱ្យចាប់អារម្មណ៍ ព្រមទាំងបានបង្ហាញពីភាពសម្បូរបែបនៃរសជាតិអាហារ ទម្រង់សិល្បៈ និងបញ្ហាផ្សេងៗទៀត ដើម្បីលើកស្ទួយរបៀបរបបរស់នៅកាន់តែប្រសើរ។

## ប៉ុស្តិ៍ ទេសចរណ៍ រុករកតំបន់កម្សាន្តទូទាំងរាជាណាចក្រ

ចាប់ពីរមណីយដ្ឋានក្នុងរាជធានីភ្នំពេញ ជាយក្រុងជិតៗ រហូតដល់ឆ្ងាយៗ ចម្ងាយរាប់រយគីឡូម៉ែត្រនៃខេត្តរតនគិរី ក៏ដូចជា តំបន់អេកូធម្មជាតិទូទាំងប្រទេស រយៈពេលជិត១០ឆ្នាំនៃការបង្កើតទំព័រទេសចរណ៍ នៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ បានណែនាំទីតាំងកម្សាន្តរាប់រយដ៏សម្បូរបែប។

លោក David-Jaya Piot ប្រធានសមាគមសណ្ឋាគារកម្ពុជាប្រចាំនៅសៀមរាប និយាយថា៖ «បណ្តាញផ្សព្វផ្សាយក្នុងស្រុក ដូចជា កាសែតភ្នំពេញប៉ុស្តិ៍ ពិតជាមានសារៈសំខាន់ចំពោះវិស័យទេសចរណ៍ដើម្បីផ្សព្វផ្សាយឱ្យមហាជនបានដឹងពីទីកន្លែងធ្វើដំណើរប្រកបដោយសុវត្ថិភាព និងរីករាយ ជាពិសេស ក្នុងស្ថានភាពដ៏លំបាកនេះ»។

តាំងពីមុនកូវីដដល់បច្ចុប្បន្ន ទេសចរណ៍បែបសហគមន៍ នៅតែមើលឃើញពីកំណើនភ្ញៀវជាហូរហែ ដោយព្យាយាមគេចឆ្ងាយពីតំបន់មនុស្សច្រើន ហើយមួយផ្នែកក៏អរគុណដល់ការផ្សព្វផ្សាយផងដែរ។

លោក ឈឹម ឈឹម ប្រធានសហគមន៍តំបន់ស្រែកិនស្ថិតក្នុងឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺដែលបង្កើតឡើងក្នុងឆ្នាំ ២០០៤ និយាយថា តាំងពីរដ្ឋាភិបាលអនុញ្ញាតឱ្យបើករមណីយដ្ឋានទេសចរណ៍វិញ មានភ្ញៀវជាច្រើនដែលក្នុងមួយសប្តាហ៍ចន្លោះពី ៣ ទៅ ៥ក្រុម ទៅលេងទឹកធ្លាក់ជើងភ្នំ និងទីកន្លែងថ្មីៗ ទាក់ទងកន្លែងយន្តហោះធ្លាក់ ដែលភ្ញៀវភាគច្រើនចង់ដឹងចង់ស្គាល់។ ពួកគាត់សម្រាកពី ២ ទៅ ៣យប់ នៅលើខ្នងភ្នំឱរ៉ាល់។

លោកប្រាប់ភ្នំពេញប៉ុស្តិ៍ថា៖ «ច្បាស់ណាស់! តាមរយៈការផ្សព្វផ្សាយ ភ្ញៀវបានដឹងច្រើនអំពីតំបន់ទេសចរណ៍ ហើយយើងទទួលភ្ញៀវថ្មីៗជាច្រើននាក់»។

យុវជនកូនកាត់ខ្មែរ-បារាំង David ក៏ជាសហស្ថាបនិក Kulen Elephant Forest បាននិយាយថា៖ «ខ្ញុំសូមកោតសរសើរកាសែតភ្នំពេញ ប៉ុស្តិ៍ លើការផ្សព្វផ្សាយព័ត៌មានមានសុក្រឹតភាព។ អរគុណចំពោះការចំណាយពេលសរសេរអត្ថបទមានតុល្យភាព និងមានការស្រាវជ្រាវច្បាស់លាស់។ អបអរខួប ២៨ឆ្នាំ»។



យុវតីខ្មែរគ្រងឈុតសម័យបុរាណខ្មែរ និងលេងឧបករណ៍រនាត បំណាងថតរូបអនុស្សាវរីយ៍។ រូបថត យូសុះ អាប់ឌុលរ៉ាស់ហ៊ីម

## ភោជនីយដ្ឋានបម្រើមុខម្ហូបចម្រុះជាតិសាសន៍

ភោជនីយដ្ឋានជាច្រើន ដែលបម្រើមុខម្ហូបខ្មែរ រួមទាំងថៃ វៀតណាម ឥណ្ឌា ប៉ាគីស្ថាន តួកគី និងអឺរ៉ុប ត្រូវបានចុះផ្សាយលើកាសែតភ្នំពេញប៉ុស្តិ៍ ទាំងភាសាខ្មែរ និងអង់គ្លេស។

ដោយទទួលស្គាល់ពីប្រសិទ្ធភាពនៃការផ្សព្វផ្សាយ ម្ចាស់ហាង Burger-shack ទីតាំងនៅក្នុងសង្កាត់បឹងកេងកង ១ ខណ្ឌបឹងកេងកង និងនៅខេត្តកំពត បានកោតសរសើរចំពោះការចុះផ្សាយរបស់កាសែត ភ្នំពេញប៉ុស្តិ៍ ប្រកបដោយវិជ្ជាជីវៈ។





ក្រុមសៀកបង្ហាញសមត្ថភាពព្រួសភ្លើងក្នុងការសម្តែងនៅឆ្នាំ២០១៧។ រូប ហេង ជីវ័ន



ទិដ្ឋភាពពិព័រណ៍ភ្នំពេញសិល្បៈនៅវិចិត្រសាលក្នុង Factory Phnom Penh។ រូបថត ហ៊ាន រង្សី

លោក Luke Macdonald និងភរិយា Holly Churchill បាននិយាយថា៖ «យើងពេញចិត្តដែលភ្នំពេញប៉ុស្តិ៍ បោះពុម្ព ទាំងជាភាសាអង់គ្លេស និងខ្មែរ ដោយមិត្តភក្តិ គ្រួសារ និងអតិថិជនមានមោទនភាពដែលយើងត្រូវបានចុះផ្សាយក្នុងកាសែតដ៏ល្បីនេះ។ យើងអរគុណភ្នំពេញ ប៉ុស្តិ៍ ដែលបានគាំទ្រអាជីវកម្មឯករាជ្យក្នុងស្រុកមួយនេះ»។

Princella Anum Gill បានរើផ្ទះពីប៉ាគីស្ថានមកកាន់កម្ពុជា និងបានបើកភោជនីយដ្ឋានដើម្បីបម្រើមុខម្ហូបប៉ាគីស្ថាន និងឥណ្ឌាក្នុងសង្កាត់ទួលទំពូង Princella Flavors of Saffron ក្នុងឆ្នាំ២០០០។

កញ្ញា Gill បាននិយាយថា៖ «យើងពិតជាពេញចិត្តទៅលើអត្ថបទដែលភ្នំពេញ ប៉ុស្តិ៍ បានសរសេរអត្ថបទសម្រាប់ភោជនីយដ្ឋានរបស់យើង។ វាពិតជាបទពិសោធដ៏ល្អ ហើយតាមរយៈអត្ថបទនេះ យើងទទួលបាននូវលទ្ធផលវិជ្ជមានយ៉ាងច្រើន។ យើងពិតជាអរគុណណាស់ចំពោះកាសែតភ្នំពេញ ប៉ុស្តិ៍»។

> ខ្ញុំសូមកោតសរសើរចំពោះកាសែតភ្នំពេញ-ប៉ុស្តិ៍ លើការផ្សព្វផ្សាយព័ត៌មានសុក្រឹតភាព។ អរគុណចំពោះការចំណាយពេលសរសេរអត្ថបទមានតុល្យភាព និងមានការស្រាវជ្រាវច្បាស់លាស់។ អបអរខួប ២៨ឆ្នាំ!



ភ្ញៀវទេសចរទៅទស្សនាទីឋានយន្តហោះធ្លាក់នៅលើកំពូលភ្នំឱរ៉ាល់។ រូបថត ហុង មិនា

អំឡុងពេលវិបត្តិកូវីដនេះ ភោជនីយដ្ឋានទាំង២នៅបន្តបើកទ្វារស្វាគមន៍ភ្ញៀវ បើទោះបីជាជួបការលំបាកដូចបណ្តាភោជនីយដ្ឋានដទៃទៀតយ៉ាងណាក៏ដោយ។

## ភ្នំពេញប៉ុស្តិ៍ បន្តលើកស្ទួយវប្បធម៌ និងសិល្បៈគ្រប់ទម្រង់

កញ្ញា ឡូរ៉េន អ៊ីអិដា ជានាយិកានៃអូផេនស្ទូឌីយោបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនថា ភ្នំពេញប៉ុស្តិ៍ តែងតែបានផ្តោតសំខាន់នូវរាល់ព្រឹត្តិការណ៍សិល្បៈ និងបង្ហាញក្រុមវិចិត្រករមានក្នុងប្រទេសកម្ពុជា ដែលអាចជួយគាំទ្រដល់ក្រុមវិចិត្រករ និងភ្នាក់ងារវិចិត្រសាលនានា មានឱកាសបង្ហើបបង្ហាញពីជំនាញចំណេះដឹងផ្នែកសិល្បៈនៅកម្ពុជា និងជួយផ្សព្វផ្សាយពីស្នាដៃពួកគេឱ្យសាធារណជនយល់ដឹង។

កញ្ញានិយាយថា៖ «យើងសង្ឃឹមថាភ្នំពេញប៉ុស្តិ៍ នឹងបន្តកិច្ចការបែបនេះទៀត សម្រាប់ជួយផ្សព្វផ្សាយអំពីព្រឹត្តិការណ៍សិល្បៈផ្សេងៗ មិនថាតែនៅអូផេនស្ទូឌីយោ នោះទេ គឺគ្រប់បណ្តាអង្គភាពផ្នែកសិល្បៈនានានៅប្រទេសកម្ពុជា»។

ជាអ្នកតាមដានកាសែតភ្នំពេញប៉ុស្តិ៍ ជាប្រចាំម្នាក់ លោក ជា សុភាព ជានាយកប្រតិបត្តិនៃមជ្ឈមណ្ឌលបុប្ផាណា បានឱ្យដឹងថា ភ្នំពេញប៉ុស្តិ៍ មានសកម្មផុសផុលខ្លាំងក្នុងការបង្ហើបបង្ហាញ ជូនដំណឹង និងចែករំលែកនូវចំណេះដឹង ផ្នែកសិល្បៈ វប្បធម៌ទៅដល់សាធារណជន។

លោកនិយាយថា៖ «កាសែតនេះ ក៏មានវិជ្ជាជីវៈខ្ពស់ដែរ ក្នុងការផ្តល់នូវទំនុកចិត្ត សុក្រឹតភាព និងអព្យាក្រឹតភាព នៃការចែកជូនព័ត៌មាន ដល់អ្នកអាន លើផ្នែកសិល្បៈ វប្បធម៌ និងជាបណ្តុំនៃព័ត៌មានជាច្រើន ដូចជាព្រឹត្តិការណ៍រៀបចំសិល្បៈ វប្បធម៌ មិនថាជាការប្រារព្ធក្នុងមជ្ឈមណ្ឌលបុប្ផាណា ឬនៅកន្លែងផ្សេងៗនោះទេ»។

លោក ប៉ោយ ឈុនលី ជាសិល្បករ និងគ្រូបង្រៀនជំនាញគំនូរជីវចល និងវីដេអូ នៅសាលាហ្វារពន្លឺសិល្បៈ បានបង្ហើបថា៖ «រាល់ការចុះផ្សាយរបស់កាសែតភ្នំពេញប៉ុស្តិ៍ លើវិស័យសិល្បៈ រហូតមកគឺជួយជ្រោមជ្រែង និងជាយុទ្ធសាស្ត្រដ៏ខ្លាំងមួយក្នុងការបំផុស និងលើកទឹកចិត្តដល់សិល្បករផ្ទាល់ ឱ្យមានកម្លាំងចិត្តបន្តការងារខ្លួន»។

លោកបន្តថា៖ «សិល្បករទាំងអស់ សូមអរគុណដល់ភ្នំពេញប៉ុស្តិ៍ ដែលតែងតែជួយផ្សព្វផ្សាយកន្លងមក និងសុំឱ្យកាសែតនេះនៅតែបន្តចុះផ្សាយ ដើម្បីជួយឱ្យវិស័យសិល្បៈខ្មែរយើងកាន់តែរីកចម្រើនទៅមុខតទៀត»៕ ■



ម្ហូបឈុតសាច់គោពិសេសពីភោជនីយដ្ឋានស៊ុបគោខ្មែរសៀមរាប។ រូបថត យូសុះ អាប់ឌុលរ៉ាស់ហ៊ីម



ប្តីប្រពន្ធម្ចាស់ភោជនីយដ្ឋាន Burger Shack។ រូបថត ហុង មិនា

# កសាងភាពជាដៃគូយុទ្ធសាស្ត្រដ៏រឹងមាំនិងយូរអង្វែង













Post Photographers



# សកម្មភាពផ្សេងៗរបស់គ្រួសារកាសែតភ្នំពេញប៉ុស្តិ៍ នៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ










Post Photographers






# ប៉ុស្តិ៍ ឌីជីថល (ខែមិថុនា ២០២០-ខែមិថុនា ២០២១)






CGCC
CREDIT GUARANTEE CORPORATION OF CAMBODIA PLC

ផ្ដល់
# ការធានាឥណទាន លើកម្ចី



ផ្ដល់ការធានាឥណទានលើកម្ចីអាជីវកម្ម ដោយដើរតួជាផ្នែកមួយនៃទ្រព្យបញ្ចាំ ដើម្បីគាំទ្រដល់អាជីវកម្មដែលខ្វះទ្រព្យបញ្ចាំ ក្នុងការស្នើសុំកម្ចី

អបអរសាទរ
ភ្នំពេញ ប៉ុស្ដិ៍ The Phnom Penh Post
29th ANNIVERSARY
THE PHNOM PENH POST

ទំនាក់ទំនងពួកយើងតាមរយៈ
info@cgcc.com.kh
www.cgcc.com.kh
023 722 123

## អបអរសាទរ ខួបលើកទី២៩ នៃកាសែតភ្នំពេញប៉ុស្ដិ៍
CONGRATULATIONS PHNOM PENH POST ON YOUR 29TH ANNIVERSARY



YI SANG chinese restaurant 鱼生 est. 2008

ដឹកជញ្ជូនដល់គេហដ្ឋាន កម្ម៉ង់ខ្ចប់ និងទទួលទានអាហារនៅក្នុងហាង
HOME DELIVERY - TAKE AWAY & DINE-IN
拨通电话
美味到家

YI SANG SOTHEAROS
Hotline: 012 814 488
Nº 128F, Sothearos Boulevard, Tonle Bassac, Corner of the Russian Embassy, Phnom Penh, Cambodia.

YI SANG THE GARDEN TOUL KORK
Hotline: 085 208 777
Nº 13, St. 337, Khan Toul Kork, Phnom Penh, Cambodia.

YI SANG RIVERSIDE
Hotline: 016 320 808
Tourist Information Centre Riverside, Sisowath Quay, Next to Chaktomuk Theater, Phnom Penh, Cambodia.

ផលិតផលបន្ថែម

# សុវណ្ណភូមិ ឡាយហ្វ៍

នៅទីនេះដើម្បីអ្នក នៅទីនេះដើម្បីកម្ពុជា

## SMILE ឡាយហ្វ៍

## ការពារជំងឺមហារីក

ទឹកប្រាក់សម្រាប់ព្យាបាលជំងឺមហារីកមានទំហំរហូតដល់

# $100,000*

ព្រមទាំងអត្ថប្រយោជន៍ចំណាយមន្ទីរពេទ្យប្រចាំថ្ងៃ



*សម្រាប់ការព្យាបាលជំងឺមហារីកកម្រិតធ្ងន់ និងកម្រិតស្រាល។ ខ និងលក្ខខណ្ឌត្រូវបានអនុវត្ត។

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត | 1800 212288 (ឥតគិតថ្លៃ)